

ឯកសារគម្ពីរព្រះត្រៃបិដកស្កេននេះ
ត្រូវបានថតចេញពីច្បាប់គម្ពីរព្រះត្រៃបិដកដប៉ុន ៗ

ឯកសារគម្ពីរព្រះត្រៃបិដកនេះ ចាប់ពីភាគ៥១ ដល់ ភាគ១១០
ត្រូវបានរៀបចំធ្វើឡើងដោយ គេហទំព័រ៥000ឆ្នាំ បូជា
ចំពោះព្រះពុទ្ធសាសនា សម្រាប់ជាធម្មទាន ៗ

ផ្តល់សៀវភៅគម្ពីរព្រះត្រៃបិដកសម្រាប់ការងារ
ដោយ ឧបាសិកា កាំង ហ្គិចណៃ ៗ

គ្រប់គ្រងគម្រោង (ទូទៅ និងផ្នែកបច្ចេកទេស)
ដោយ ឧបាសក ស្រុង-ចាន់ណា ៗ

ត្រួតពិនិត្យឡើងវិញ
ដោយ ចន-ស្រីស្រស់ ៗ

ថតស្កេនដោយ
ប្អូនប្រុស ម៉ាន់ សាវ៉េត

www.5000-years.org

ក្រោមការឧបត្ថម្ភយ៉ាងច្រើនលើសលប់អំពី៖

- ឧបាសិកា កាំង ហ៊ុចហ័ណ (ភ្នំពេញ)
- ឧបាសក ជុត លីស្រុង និង ឧបាសិកា លី សុខា ព្រមទាំងបុត្រ (ភ្នំពេញ)
- ឧបាសក សន ចន និង ឧបាសិកា អ៊ួច សាទៀង ព្រមទាំងបុត្រ (បាត់ដំបង)
- ឧបាសក ជា ស៊ុវត្ថានា និងឧបាសិកា ឃុន សូនីម៉ា ព្រមទាំងបុត្រី ជា សុមេធាធីតា (ស.រ.អ)
- លោក ជឹម-ជា និងលោកស្រី រតនី ស្រីមុំ (ភ្នំពេញ)
- ឧបាសក ផែង យឿន (កូរ៉េ)
- លោក ស៊ុក ចាន់សេរី (បន្ទាយមានជ័យ)
- ឧបាសិកា យ៉ា វ៉ារី (បន្ទាយមានជ័យ)
- ប្អូនស្រី យ៉ា សុភ: (បន្ទាយមានជ័យ)
- ឧបាសិកា កោ សេង (ភ្នំពេញ)
- លោកស្រី ប៉ាន សុគន្ធានីន និងស្វាមី ព្រមទាំងបុត្រ (ភ្នំពេញ)
- ឧបាសក ស្រុង ចាន់ណា និង ឧបាសិកា ចន ស្រីស្រស់
ព្រមទាំងបុត្រ ចាន់ណា សុធារនីរាជ, ចាន់ណា សុធារនិរោធ (ភ្នំពេញ)
- លោកស្រី ស្រុង ចាន់រស្មី និង ស្វាមី ព្រមទាំងបុត្រ (ភ្នំពេញ)
- កញ្ញា ស្រុង ចាន់រតនា (ភ្នំពេញ)
- លោក ស្រុង យូហេង (ភ្នំពេញ)
- លោក នង សុផល (កូរ៉េ)
- ប្អូនស្រី សុខ អេង (កំពង់ចាម)
- កញ្ញា ចន កក្កដា (បាត់ដំបង)
- លោកស្រី ចន សត្យា និងលោក ទួត សេរីសិក ព្រមទាំងបុត្រ (ភ្នំពេញ)
- លោក ចន រចនា (បាត់ដំបង)
- កញ្ញា ស៊ែ សុផារី (បាត់ដំបង)
- កញ្ញា យឿម សុផានី (បាត់ដំបង)
- លោក ម៉ៅ គន្ធា និងលោកស្រី ធៀង សេដ្ឋា (បាត់ដំបង)
- លោក សៅ សារ៉ុម (បាត់ដំបង)
- ព្រះតេជព្រះគុណ ជុំ សារ: (ព្រះចៅអធិការវត្ត សម សាន្ត ខេត្តបាត់ដំបង)
- ឧបាសិកា វ៉ាន់ លុយ និងស្វាមី ព្រមទាំងបុត្រ (ភ្នំពេញ)
- លោកស្រី ហួ ច័ន្ទសុវណ្ណ និងស្វាមី ព្រមទាំងបុត្រ (ស.រ.អ)

# ព្រះ
# ត្រៃបិដកបាលី
## និង
# សេចក្តីប្រែជាភាសាខ្មែរ
# អភិធម្មបិដក
# បដ្ឋាន តតិយភាគ
# ៩៦

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ព.ស. ២៥១០

## ឧទ្ទិសកថា

យើងខ្ញុំ សូមផ្តង់ស្មារតីសូត្រព្រះធម៌ឧទ្ទិសជូនជនជាតិខ្មែរ ។

ឥឡូវ យើងខ្ញុំអាចជូនគម្ពីរព្រះត្រៃបិដកនេះ ទៅអ្នកកាន់ព្រះពុទ្ធសាសនាជនជាតិខ្មែរបានហើយ ។

ព្រះធម៌នៃព្រះពុទ្ធជាម្ចាស់នេះ ត្រូវបានសូត្រចេញពីជម្រៅដួងចិត្តនៃអ្នកកាន់ព្រះពុទ្ធសាសនា
ជនជាតិជប៉ុន ។

このカンボジア版南伝大蔵経を
カンボジアの佛教徒へ
贈ることができることに感謝します。
これが日本の佛教徒の心です。

It is with a deep sense of gratitude that I present the translation of the complete collection of " TRIPITAKA " to the Cambodian Buddhists on behalf of the Japanese Buddhist community.

# អារម្ភកថា

ជូនចំពោះជនជាតិខ្មែរ ជាទីរាប់អាន !

ជូនចំពោះជនជាតិខ្មែរដែលកាន់ព្រះពុទ្ធសាសនា ជាទីគោរព !

គម្ពីរព្រះត្រៃបិដកខ្មែរនេះ ត្រូវបាន " ក្រុមជំនុំព្រះត្រៃបិដក " នៃពុទ្ធសាសនបណ្ឌិត្យនៅភ្នំពេញ បកប្រែពីភាសាបាលីមកជាភាសាខ្មែរ តាំងពីឆ្នាំ ១៩៣០ ទៅឆ្នាំ ១៩៦៨ គឺត្រូវចំណាយពេល ៣៩ ឆ្នាំ ទើបបានសម្រេចហើយសព្វគ្រប់ ។ នេះពិតជាកំណាប់ព្រះធម៌របស់ព្រះពុទ្ធសាសនាខ្មែរ ហើយក៏ជាកំណាប់វប្បធម៌ខាងផ្នែកបោះពុម្ពរបស់ជនជាតិខ្មែរផងដែរ ។ យើងខ្ញុំ ពុទ្ធសាសនិកជាតិជប៉ុន មានសន្តានចិត្តរីករាយនឹងបោះពុម្ពជាថ្មីឡើងវិញ ដោយសង្ឃឹមថា ព្រះពុទ្ធសាសនាខ្មែរក៏នឹងរុងរឿងឡើងវិញដែរ ។

នេះគឺជាអំណោយពីជម្រៅដួងចិត្ត ជូនទៅដល់ជនជាតិខ្មែរទាំងអស់ ព្រមទាំងមនុស្សជាតិទូទៅ នៅក្នុងពិភពលោកនេះ ដែលមានចិត្តស្រឡាញ់សន្តិភាព ។

ខ្មែរបានរងសោកនាដកម្មដែលមិនធ្លាប់មានពីមុនមក ។ ម្យ៉ាងទៀត ព្រះពុទ្ធសាសនាខ្មែរ ក៏ត្រូវអន្តរាយយ៉ាងខ្លាំង ក៏ប៉ុន្តែឥឡូវនេះ យើងទាំងអស់គ្នា បានឈានជើងកន្លងផុតពីសេចក្តីទុក្ខសោកដ៏ធ្ងន់ធ្ងរនេះ ចាកផុតពីអំពើឃោរឃៅ បញ្ចប់គំនុំគុំគួន ដើរតាមពុទ្ធដីកាព្រះបរមគ្រូខិតខំព្យាយាមធ្វើឱ្យមានសន្តិភាពក្នុងពិភពលោក ។

ការណ៍ដែលយើងខ្ញុំជូនគម្ពីរព្រះត្រៃបិដកពេលនេះ គឺជានិមិត្តរូបនៃការប្តេជ្ញាចិត្តរបស់អ្នកកាន់ព្រះពុទ្ធសាសនាជនជាតិជប៉ុនថា យើងខ្ញុំធ្វើសហប្រតិបត្តិការដើម្បីសន្តិភាពក្នុងពិភពលោក ដើម្បីទុកជាភស្តុតាងនៃចំណងមេត្រីភាព និងមិត្តភាពរវាងប្រជាជាតិជប៉ុន និងប្រជាជាតិខ្មែរ ។

ថ្ងៃនក្ខត្តឫក្ស កក្កដា ឆ្នាំ ១៩៩៤

សមាគមជំនួយដល់ការបោះពុម្ពព្រះត្រៃបិដកឡើងវិញ

អ្នកតំណាងចាត់ការ Rev. Muchaku Seikyo

ប្រធានការិយាល័យ Rev. Sinohara Eiichi

អ្នកចាត់ការ Rev. Matunaga Zendo Rev. Arima Jitsujo Rev. Ito Yoshimichi Rev. Watai Keiichi Rev. Sugiya Yoshizumi Rev. Sigeta Shincyo Rev. Maeda Risyo Rev. Nakajima Kyoshi Mr. Ei Rokusuke

# 『トリピタカ』復刻進呈にあたって

親愛なるカンボジアの皆さん！
敬愛するカンボジアの仏教徒の皆さん！

カンボジア版『トリピタカ』は、プノンペンの仏教研究所が、仏教界の英知を集め、1930年から1968年まで、39年の歳月をかけて翻訳し、分類し、集大成して完成されました。まさにカンボジア仏教の法宝であると共に、カンボジア出版文化の至宝です。日本仏教徒の有志は、カンボジア仏教の復興再生を願いつつ、これを復刻刊行し、贈らせていただきます。

これはカンボジア仏教徒のみならず、カンボジア全人民、否、平和を愛する地球上のすべての人々への、心からの贈り物です。

カンボジアは、古今未曾有の悲劇を体験しました。カンボジア仏教もこの受難の時代に壊滅的な打撃を受けました。しかし、今はその悲しみを乗りこえ、瞋りを離れ、怨みを恕し、ブッダの教えに従い、世界平和の実現に努力するときです。

この本の贈呈は、日本の仏教徒も共々に、世界平和のために努力することを誓うしるしであり、相互の連帯と友情の証なのです。

合掌

1994年7月吉日

カンボジア版トリピタカ（南伝大蔵経）復刻救援委員会

世話人代表　無着　成恭
事務局長　篠原　鋭一

世話人　松永　然道　有馬　実成
伊藤　佳通　渡井　奎一
杉谷　義純　茂田　真澄
前田　利勝　中島　教之
永　六輔

# Acknowledgment

My dear Cambodian friends and respected members of the Cambodian Buddhist community.

It gives me a great pleasure to learn that the translation of the " Pali Tripitaka " into Cambodian by the " Tripitaka Commission " of the Buddhist Institute, Phnom Penh has been successfully achieved. The project to translate the Tripitaka was launched in 1930 and took 39 years to complete the whole work only in 1968.

The Cambodian translation of this great work will not only become a cherished treasure of the Cambodian Buddhist community but is also an important milestone in the history of publication in Cambodia.

Revival and prosperity of Buddhism in Cambodia is the ardent desire of the Japanese Buddhist Community. It is with this spirit that we have completed this important project and want to present the complete work to the Cambodian Buddhist community. It is a present not only to the Buddhist community in Cambodia but also to the Cambodian people and all the peace loving people in the world.

Cambodia experienced the greatest tragedies of modern times and the Cambodian Buddhist community also underwent severe trials and suffered crushing blows during this period. But now a time has come to surmount this grief and anger, and to forgive and start working again for world peace.

This great work is a symbol of Japanese Buddhist communities resolve to work with our Cambodian brothers and sisters toward world peace and a testimony to the friendship between the people.

Join hands in prayer...
July 1994

TRIPITAKA PUBLISHING SUPPORT COMMITTEE
Project Manager: Rev. Seikyo Muchaku
Secretary General: Rev. Eiichi Sinohara
Management Team:
Rev. Zendo Matunage Rev. Jitsujo Arima Rev. Yoshimichi Ito
Rev. Keiichi Watai Rev. Yoshizumi Sugiya Rev. Shincyo Sigeta
Rev. Risyo Maeda Rev. Kyoshi Nakajima Mr. Rokusuke Ei

[illegible]

[illegible]

[illegible]

[illegible]

អភិធម្មបិដក

បដ្ឋាន តតិយភាគ

៩៦

ព.ស. ២៥១០

# អភិធម្មបិដកេ

# បដ្ឋានស្ស តតិយោ ភាគោ

## វិបាកត្តិកំ

## បដិច្ចវារោ

(១) វិបាកំ ធម្មំ បដិច្ច វិបាកោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា វិបាកំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ។បេ។ ទ្វេ ខន្ធេ បដិច្ច ទ្វេ ខន្ធា បដិសន្ធិក្ខណេ វិបាកំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ។បេ។ ទ្វេ ខន្ធេ បដិច្ច ទ្វេ ខន្ធា ។ វិបាកំ ធម្មំ បដិច្ច នេវវិបាកនវិបាកធម្មធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា វិបាកេ ខន្ធេ បដិច្ច ចិត្តសមុដ្ឋានំ រូបំ បដិសន្ធិក្ខណេ វិបាកេ ខន្ធេ បដិច្ច កដត្តារូបំ ។ វិបាកំ ធម្មំ បដិច្ច វិបាកោ ច នេវវិបាកនវិបាកធម្មធម្មោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា វិបាកំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ចិត្តសមុដ្ឋានញ្ច រូបំ ទ្វេ ខន្ធេ បដិច្ច ទ្វេ ខន្ធា ចិត្តសមុដ្ឋានញ្ច រូបំ បដិសន្ធិក្ខណេ វិបាកំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា កដត្តា ច រូបំ ទ្វេ ខន្ធេ បដិច្ច ទ្វេ ខន្ធា កដត្តា ច រូបំ ។

# អភិធម្មបិដក

## បដ្ឋាន តតិយភាគ

---

## វិបាកត្តិកៈ

### បដិច្ចវារៈ

[១] វិបាកធម៌ អាស្រ័យវិបាកធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យវិបាកក្ខន្ធ ១ ។ បេ ។ ខន្ធ ២ អាស្រ័យខន្ធ ២ ខន្ធ ៣ អាស្រ័យវិបាកក្ខន្ធ ១ ក្នុងខណៈនៃបដិសន្ធិ ។ បេ ។ ខន្ធ ២ អាស្រ័យខន្ធ ២ ។ ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យវិបាកធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យវិបាកក្ខន្ធទាំងឡាយ កដត្តារូប អាស្រ័យវិបាកក្ខន្ធទាំងឡាយ ក្នុងខណៈនៃបដិសន្ធិ ។ វិបាកក្តី ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីក្តី អាស្រ័យវិបាកធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យវិបាកក្ខន្ធ ១ ខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ២ ខន្ធ ៣ ក្តី កដត្តារូបក្តី អាស្រ័យវិបាកក្ខន្ធ ១ ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ ក្តី កដត្តារូបក្តី អាស្រ័យខន្ធ ២ ។

(២) វិបាកធម្មធម្មំ បដិច្ច វិបាកធម្មធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា វិបាកធម្មធម្មំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ទ្វេ ខន្ធេ បដិច្ច ទ្វេ ខន្ធា ។ វិបាកធម្មធម្មំ បដិច្ច នេវវិបាកនវិបាកធម្មធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា វិបាកធម្មេ ខន្ធេ បដិច្ច ចិត្តសមុដ្ឋានំ រូបំ ។ វិបាកធម្មធម្មំ បដិច្ច វិបាកធម្មធម្មោ ច នេវវិបាកនវិបាកធម្មធម្មោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា វិបាកធម្មធម្មំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ចិត្តសមុដ្ឋានញ្ច រូបំ ទ្វេ ខន្ធេ បដិច្ច ទ្វេ ខន្ធា ចិត្តសមុដ្ឋានញ្ច រូបំ ។

(៣) នេវវិបាកនវិបាកធម្មធម្មំ បដិច្ច នេវវិបាកនវិបាកធម្មធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា នេវវិបាកនវិបាកធម្មធម្មំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ចិត្តសមុដ្ឋានញ្ច រូបំ ទ្វេ ខន្ធេ បដិច្ច ទ្វេ ខន្ធា ចិត្តសមុដ្ឋានញ្ច រូបំ ឯកំ មហាភូតំ បដិច្ច តយោ មហាភូតា ទ្វេ មហាភូតេ បដិច្ច ទ្វេ មហាភូតា មហាភូតេ បដិច្ច ចិត្តសមុដ្ឋានំ រូបំ កដត្តារូបំ ឧបាទារូបំ ។ នេវវិបាកនវិបាកធម្មធម្មំ បដិច្ច វិបាកោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា បដិសន្ធិក្ខណេ វត្ថុំ បដិច្ច វិបាកា ខន្ធា ។

(២) ធម៌មានវិបាកជាប្រក្រតី អាស្រ័យធម៌មានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ខន្ធ ៣ អាស្រ័យខន្ធ ១ ដែលជាធម៌មានវិបាកជាប្រក្រតី ខន្ធ ២ អាស្រ័យខន្ធ ២ ។ ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យធម៌មានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលជាធម៌មានវិបាកជាប្រក្រតី ។ ធម៌មានវិបាកជាប្រក្រតី ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យធម៌មានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ១ ដែលជាធម៌មានវិបាកជាប្រក្រតី ខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ២ ។

(៣) ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ១ ដែលជាធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ២ មហាភូត ៣ អាស្រ័យមហាភូត ១ មហាភូត ២ អាស្រ័យមហាភូត ២ ចិត្តសមុដ្ឋានរូប កដត្តារូប ឧបាទារូប អាស្រ័យមហាភូតទាំងឡាយ ។ វិបាកធម៌ អាស្រ័យធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ វិបាកក្ខន្ធទាំងឡាយ អាស្រ័យវត្ថុ ក្នុងខណៈនៃបដិសន្ធិ ។

នេវវិបាកនវិបាកធម្មធម្មំ បដិច្ច វិបាកោ ច នេវ-
វិបាកនវិបាកធម្មធម្មោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្ប-
ច្ចយា បដិសន្ធិក្ខណេ វត្ថុំ បដិច្ច វិបាកា ខន្ធា
មហាភូតេ បដិច្ច កដត្តារូបំ ។

(៤) វិបាកញ្ច នេវវិបាកនវិបាកធម្មធម្មញ្ច ធម្មំ
បដិច្ច វិបាកោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា
បដិសន្ធិក្ខណេ វិបាកំ ឯកំ ខន្ធញ្ច វត្ថុញ្ច បដិច្ច
តយោ ខន្ធា ទ្វេ ខន្ធេ ច វត្ថុញ្ច បដិច្ច ទ្វេ
ខន្ធា ។ វិបាកញ្ច នេវវិបាកនវិបាកធម្មធម្មញ្ច ធម្មំ
បដិច្ច នេវវិបាកនវិបាកធម្មោ ឧប្បជ្ជតិ ហេតុប្ប-
ច្ចយា វិបាកេ ខន្ធេ ច មហាភូតេ ច បដិច្ច
ចិត្តសមុដ្ឋានំ រូបំ បដិសន្ធិក្ខណេ វិបាកេ ខន្ធេ
ច មហាភូតេ ច បដិច្ច កដត្តារូបំ ។ វិបាកញ្ច
នេវវិបាកនវិបាកធម្មធម្មញ្ច ធម្មំ បដិច្ច វិបាកោ ច
នេវវិបាកនវិបាកធម្មោ ច ធម្មា ឧប្បជ្ជន្តិ ហេតុ-
ប្បច្ចយា បដិសន្ធិក្ខណេ វិបាកំ ឯកំ ខន្ធញ្ច វត្ថុញ្ច
បដិច្ច តយោ ខន្ធា ទ្វេ ខន្ធេ ច វត្ថុញ្ច បដិច្ច ទ្វេ ខន្ធា
វិបាកេ ខន្ធេ ច មហាភូតេ ច បដិច្ច កដត្តារូបំ ។

វិបាកធម៌ក្តី ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីក្តី អាស្រ័យធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ វិបាកក្ខន្ធទាំងឡាយ អាស្រ័យវត្ថុ ក្នុងខណៈនៃបដិសន្ធិ កដត្តារូប អាស្រ័យមហាភូតទាំងឡាយ ។

(៤) វិបាកធម៌ អាស្រ័យវិបាកធម៌ផង ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ខន្ធ ៣ អាស្រ័យវិបាកក្ខន្ធ ១ ផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ អាស្រ័យខន្ធ ២ ផង វត្ថុផង ។ ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យវិបាកធម៌ផង ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ចិត្តសមុដ្ឋានរូប អាស្រ័យវិបាកក្ខន្ធទាំងឡាយផង មហាភូតទាំងឡាយផង កដត្តារូប អាស្រ័យវិបាកក្ខន្ធទាំងឡាយផង មហាភូតទាំងឡាយផង ក្នុងខណៈនៃបដិសន្ធិ ។ វិបាកធម៌ក្តី ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីក្តី អាស្រ័យវិបាកធម៌ផង ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ខន្ធ ៣ អាស្រ័យវិបាកក្ខន្ធ ១ ផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ អាស្រ័យខន្ធ ២ ផង វត្ថុផង កដត្តារូប អាស្រ័យវិបាកក្ខន្ធទាំងឡាយផង មហាភូតទាំងឡាយផង ។

(៥) វិបាកធម្មធម្មញ្ច នេវវិបាកនវិបាកធម្មធម្មញ្ច ធម្មំ បដិច្ច នេវវិបាកនវិបាកធម្មធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា វិបាកធម្មធម្មេ ខន្ធេ ច មហាភូតេ ច បដិច្ច ចិត្តសមុដ្ឋានំ រូបំ ។

(៦) វិបាកំ ធម្មំ បដិច្ច វិបាកោ ធម្មោ ឧប្បជ្ជតិ អារម្មណប្បច្ចយា វិបាកំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ទ្វេ ខន្ធេ បដិច្ច ទ្វេ ខន្ធា បដិសន្ធិក្ខណេ វិបាកំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ទ្វេ ខន្ធេ បដិច្ច ទ្វេ ខន្ធា ។

(៧) វិបាកធម្មធម្មំ បដិច្ច វិបាកធម្មធម្មោ ឧប្បជ្ជតិ អារម្មណប្បច្ចយា វិបាកធម្មធម្មំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ទ្វេ ខន្ធេ បដិច្ច ទ្វេ ខន្ធា ។

(៨) នេវវិបាកនវិបាកធម្មធម្មំ បដិច្ច នេវវិបាកនវិបាកធម្មធម្មោ ឧប្បជ្ជតិ អារម្មណប្បច្ចយា នេវវិបាកនវិបាកធម្មធម្មំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ទ្វេ ខន្ធេ បដិច្ច ទ្វេ ខន្ធា ។ នេវវិបាកនវិបាកធម្មធម្មំ បដិច្ច វិបាកោ ធម្មោ ឧប្បជ្ជតិ អារម្មណប្បច្ចយា បដិសន្ធិក្ខណេ វត្ថុំ បដិច្ច វិបាកា ខន្ធា ។

(៥) ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យធម៌មានវិបាកជាប្រក្រតីផង ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលជាធម៌មានវិបាកជាប្រក្រតីផង មហាភូតទាំងឡាយផង ។

(៦) វិបាកធម៌ អាស្រ័យវិបាកធម៌ ទើបកើតឡើង ព្រោះអារម្មណ-ប្បច្ច័យ គឺ ខន្ធ ៣ អាស្រ័យវិបាកក្ខន្ធ ១ ខន្ធ ២ អាស្រ័យខន្ធ ២ ខន្ធ ៣ អាស្រ័យវិបាកក្ខន្ធ ១ ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ អាស្រ័យខន្ធ ២ ។

(៧) ធម៌មានវិបាកជាប្រក្រតី អាស្រ័យធម៌មានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺ ខន្ធ ៣ អាស្រ័យខន្ធ ១ ដែលជាធម៌មានវិបាកជាប្រក្រតី ខន្ធ ២ អាស្រ័យខន្ធ ២ ។

(៨) ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺ ខន្ធ ៣ អាស្រ័យខន្ធ ១ ដែលជាធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ខន្ធ ២ អាស្រ័យខន្ធ ២ ។ វិបាកធម៌ អាស្រ័យធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺ វិបាកក្ខន្ធទាំងឡាយ អាស្រ័យវត្ថុ ក្នុងខណៈនៃបដិសន្ធិ ។

វិបាកត្តិកេ បដិច្ចវារោ

(៩) វិបាកញ្ច នេវវិបាកនវិបាកធម្មធម្មញ្ច ធម្មំ បដិច្ច វិបាកោ ធម្មោ ឧប្បជ្ជតិ អារម្មណប្បច្ចយា បដិសន្ធិក្ខណេ វិបាកំ ឯកំ ខន្ធញ្ច វត្ថុញ្ច បដិច្ច តយោ ខន្ធា ទ្វេ ខន្ធេ ច វត្ថុញ្ច បដិច្ច ទ្វេ ខន្ធា ។

(១០) វិបាកំ ធម្មំ បដិច្ច វិបាកោ ធម្មោ ឧប្បជ្ជតិ អធិបតិប្បច្ចយា វិបាកំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ទ្វេ ខន្ធេ បដិច្ច ទ្វេ ខន្ធា ។ វិបាកំ ធម្មំ បដិច្ច នេវវិបាកនវិបាកធម្មធម្មោ ឧប្បជ្ជតិ អធិបតិប្បច្ចយា វិបាកេ ខន្ធេ បដិច្ច ចិត្តសមុដ្ឋានំ រូបំ ។ វិបាកំ ធម្មំ បដិច្ច វិបាកោ ច នេវវិបាកនវិបាកធម្មធម្មោ ច ធម្មា ឧប្បជ្ជន្តិ អធិបតិប្បច្ចយា វិបាកំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ចិត្តសមុដ្ឋានញ្ច រូបំ ទ្វេ ខន្ធេ បដិច្ច ទ្វេ ខន្ធា ចិត្តសមុដ្ឋានញ្ច រូបំ វិបាកធម្មធម្មំ បដិច្ច តីណិ ។

(១១) នេវវិបាកនវិបាកធម្មធម្មំ បដិច្ច នេវវិបាកនវិបាកធម្មធម្មោ ឧប្បជ្ជតិ អធិបតិប្បច្ចយា នេវវិបាកនវិបាកធម្មធម្មំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ចិត្តសមុដ្ឋានញ្ច រូបំ ទ្វេ ខន្ធេ បដិច្ច ទ្វេ ខន្ធា ចិត្តសមុដ្ឋានញ្ច រូបំ ឯកំ មហាភូតំ បដិច្ច តយោ មហាភូតា

វិបាកត្តិកៈ បដិច្ចវារៈ

(៩) វិបាកធម៌ អាស្រ័យវិបាកធម៌ផង ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីផង ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺ ខន្ធ ៣ អាស្រ័យវិបាកក្ខន្ធ ១ ផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ អាស្រ័យខន្ធ ២ ផង វត្ថុផង ។

(១០) វិបាកធម៌ អាស្រ័យវិបាកធម៌ ទើបកើតឡើង ព្រោះអធិបតិប្បច្ច័យ គឺ ខន្ធ ៣ អាស្រ័យវិបាកក្ខន្ធ១ ខន្ធ២ អាស្រ័យខន្ធ២ ។ ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យវិបាកធម៌ ទើបកើតឡើង ព្រោះអធិបតិប្បច្ច័យ គឺ ចិត្តសមុដ្ឋានរូប អាស្រ័យវិបាកក្ខន្ធទាំងឡាយ ។ វិបាកធម៌ក្តី ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីក្តី អាស្រ័យវិបាកធម៌ ទើបកើតឡើង ព្រោះអធិបតិប្បច្ច័យ គឺ ខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យវិបាកក្ខន្ធ ១ ខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ២ ខន្ធ ៣ អាស្រ័យធម៌មានវិបាកជាប្រក្រតី ។

(១១) ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះអធិបតិប្បច្ច័យ គឺ ខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ១ ដែលជាធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ២ មហាភូត ៣ អាស្រ័យមហាភូត ១

មហាភូតេ បដិច្ច ចិត្តសមុដ្ឋានំ រូបំ កដត្តារូបំ ឧបាទារូបំ ។

(១២) វិបាកញ្ច នេវវិបាកនវិបាកធម្មធម្មញ្ច ធម្មំ បដិច្ច នេវវិបាកនវិបាកធម្មធម្មោ ឧប្បជ្ជតិ អធិបតិប្បច្ចយា វិបាកេ ខន្ធេ ច មហាភូតេ ច បដិច្ច ចិត្តសមុដ្ឋានំ រូបំ ។

(១៣) វិបាកធម្មធម្មញ្ច នេវវិបាកនវិបាកធម្មធម្មញ្ច ធម្មំ បដិច្ច នេវវិបាកនវិបាកធម្មធម្មោ ឧប្បជ្ជតិ អធិបតិប្បច្ចយា វិបាកធម្មធម្មេ ខន្ធេ ច មហាភូតេ ច បដិច្ច ចិត្តសមុដ្ឋានំ រូបំ ។

(១៤) វិបាកំ ធម្មំ បដិច្ច វិបាកោ ធម្មោ ឧប្បជ្ជតិ អនន្តរប្បច្ចយា . . . សមនន្តរប្បច្ចយា . . . អារម្មណប្បច្ចយសទិសំ ។ សហជាតប្បច្ចយា . . . សហជាតំ សព្វំ ហេតុប្បច្ចយសទិសំ ។

(១៥) នេវវិបាកនវិបាកធម្មធម្មំ បដិច្ច នេវវិបាកនវិបាកធម្មធម្មោ ឧប្បជ្ជតិ សហជាតប្បច្ចយា ពាហិរំ . . . អាហារសមុដ្ឋានំ . . . ឧតុសមុដ្ឋានំ . . . អសញ្ញសត្តានំ ។ សហជាតេ ឥទំ នានាករណំ ។

ចិត្តសមុដ្ឋានរូប កដត្តារូប ឧបាទារូប អាស្រ័យមហាភូតទាំងឡាយ ។

(១២) ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យវិបាកធម៌ផង ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីផង ទើបកើតឡើង ព្រោះអធិបតិប្បច្ច័យ គឺ ចិត្តសមុដ្ឋានរូប អាស្រ័យវិបាកក្ខន្ធទាំងឡាយផង មហាភូតទាំងឡាយផង ។

(១៣) ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យធម៌មានវិបាកជាប្រក្រតីផង ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីផង ទើបកើតឡើង ព្រោះអធិបតិប្បច្ច័យ គឺ ចិត្តសមុដ្ឋានរូប អាស្រ័យពួកខន្ធ ដែលជាធម៌មានវិបាកជាប្រក្រតីផង មហាភូតទាំងឡាយផង ។

(១៤) វិបាកធម៌ អាស្រ័យវិបាកធម៌ ទើបកើតឡើង ព្រោះអនន្តរប្បច្ច័យ . . . ព្រោះសមនន្តរប្បច្ច័យ . . . ប្រហែលគ្នានឹងអារម្មណប្បច្ច័យដែរ ។ ព្រោះសហជាតប្បច្ច័យ . . . សហជាតប្បច្ច័យទាំងអស់ ប្រហែលគ្នានឹងហេតុប្បច្ច័យដែរ ។

(១៥) ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះសហជាតប្បច្ច័យ គឺ ពាហិររូប . . . អាហារសមុដ្ឋានរូប . . . ឧតុសមុដ្ឋានរូប . . . របស់ពួកអសញ្ញសត្វ ។ គប្បីធ្វើឲ្យស្មើ ៗ គ្នា នេះ ក្នុងសហជាតប្បច្ច័យ ។

(១៦) វិបាកំ ធម្មំ បដិច្ច វិបាកោ ធម្មោ ឧប្បជ្ជតិ អញ្ញមញ្ញប្បច្ចយា វិបាកំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ទ្វេ ខន្ធេ បដិច្ច ទ្វេ ខន្ធា បដិសន្ធិក្ខណេ វិបាកំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ទ្វេ ខន្ធេ បដិច្ច ទ្វេ ខន្ធា ។ វិបាកំ ធម្មំ បដិច្ច នេវវិបាកនវិបាកធម្មធម្មោ ឧប្បជ្ជតិ អញ្ញមញ្ញប្បច្ចយា បដិសន្ធិក្ខណេ វិបាកេ ខន្ធេ បដិច្ច វត្ថុ ។ វិបាកំ ធម្មំ បដិច្ច វិបាកោ ច នេវវិបាកនវិបាកធម្មធម្មោ ច ធម្មា ឧប្បជ្ជន្តិ អញ្ញមញ្ញប្បច្ចយា បដិសន្ធិក្ខណេ វិបាកំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា វត្ថុ ច ទ្វេ ខន្ធេ បដិច្ច ទ្វេ ខន្ធា វត្ថុ ច ។

(១៧) វិបាកធម្មធម្មំ បដិច្ច វិបាកធម្មធម្មោ ឧប្បជ្ជតិ អញ្ញមញ្ញប្បច្ចយា វិបាកធម្មធម្មំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ទ្វេ ខន្ធេ បដិច្ច ទ្វេ ខន្ធា ។

(១៨) នេវវិបាកនវិបាកធម្មធម្មំ បដិច្ច នេវវិបាកនវិបាកធម្មធម្មោ ឧប្បជ្ជតិ អញ្ញមញ្ញប្បច្ចយា នេវវិបាកនវិបាកធម្មធម្មំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ឯកំ មហាភូតំ . . . ពាហិរំ . . . អាហារសមុដ្ឋានំ . . . ឧតុសមុដ្ឋានំ . . .

(១៦) វិបាកធម៌ អាស្រ័យវិបាកធម៌ ទើបកើតឡើង ព្រោះអញ្ញមញ្ញប្បច្ច័យ គឺ ខន្ធ ៣ អាស្រ័យវិបាកក្ខន្ធ ១ ខន្ធ ២ អាស្រ័យខន្ធ ២ ខន្ធ ៣ អាស្រ័យវិបាកក្ខន្ធ ១ ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ អាស្រ័យខន្ធ ២ ។ ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យវិបាកធម៌ ទើបកើតឡើង ព្រោះអញ្ញមញ្ញប្បច្ច័យ គឺ វត្ថុ អាស្រ័យវិបាកក្ខន្ធទាំងឡាយ ក្នុងខណៈនៃបដិសន្ធិ ។ វិបាកធម៌ក្តី ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីក្តី អាស្រ័យវិបាកធម៌ ទើបកើតឡើង ព្រោះអញ្ញមញ្ញប្បច្ច័យ គឺ ខន្ធ ៣ ក្តី វត្ថុក្តី អាស្រ័យវិបាកក្ខន្ធ ១ ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ ក្តី វត្ថុក្តី អាស្រ័យខន្ធ ២ ។

(១៧) ធម៌មានវិបាកជាប្រក្រតី អាស្រ័យធម៌មានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះអញ្ញមញ្ញប្បច្ច័យ គឺ ខន្ធ ៣ អាស្រ័យខន្ធ ១ ដែលជាធម៌មានវិបាកជាប្រក្រតី ខន្ធ ២ អាស្រ័យខន្ធ ២ ។

(១៨) ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះអញ្ញមញ្ញប្បច្ច័យ គឺ ខន្ធ ៣ អាស្រ័យខន្ធ ១ ដែលជាធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី មហាភូត ១ . . . ពាហិររូប . . . អាហារសមុដ្ឋានរូប . . . ឧតុសមុដ្ឋានរូប . . . (មហាភូត ៣

អសញ្ញសត្តានំ ឯកំ មហាភូតំ ។ នេវវិបាក-នវិបាកធម្មធម្មំ បដិច្ច វិបាកោ ធម្មោ ឧប្បជ្ជតិ អញ្ញមញ្ញប្បច្ចយា បដិសន្ធិក្ខណេ វត្ថុំ បដិច្ច វិបាកា ខន្ធា ។

(១៩) វិបាកញ្ច នេវវិបាកនវិបាកធម្មធម្មញ្ច ធម្មំ បដិច្ច វិបាកោ ធម្មោ ឧប្បជ្ជតិ អញ្ញមញ្ញ-ប្បច្ចយា បដិសន្ធិក្ខណេ វិបាកំ ឯកំ ខន្ធញ្ច វត្ថុញ្ច បដិច្ច តយោ ខន្ធា ទ្វេ ខន្ធេ ច វត្ថុញ្ច បដិច្ច ទ្វេ ខន្ធា ។

(២០) វិបាកំ ធម្មំ បដិច្ច វិបាកោ ធម្មោ ឧប្បជ្ជតិ និស្សយប្បច្ចយា ។ សង្ខិត្តំ ។ ឧប-និស្សយប្បច្ចយា បុរេជាតប្បច្ចយា ។

(២១) វិបាកធម្មធម្មំ បដិច្ច វិបាកធម្មធម្មោ ឧប្បជ្ជតិ អាសេវនប្បច្ចយា វិបាកធម្មធម្មំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ទ្វេ ខន្ធេ បដិច្ច ទ្វេ ខន្ធា ។

(២២) នេវវិបាកនវិបាកធម្មធម្មំ បដិច្ច នេវវិ-បាកនវិបាកធម្មធម្មោ ឧប្បជ្ជតិ អាសេវនប្បច្ចយា នេវវិបាកនវិបាកធម្មធម្មំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ទ្វេ ខន្ធេ បដិច្ច ទ្វេ ខន្ធា ។

អាស្រ័យមហាភូត ១ របស់ពួកអសញ្ញសត្វ ។ វិបាកធម៌ អាស្រ័យធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះអញ្ញមញ្ញប្បច្ច័យ គឺ វិបាកក្ខន្ធទាំងឡាយ អាស្រ័យវត្ថុ ក្នុងខណៈនៃបដិសន្ធិ ។

(១៩) វិបាកធម៌ អាស្រ័យវិបាកធម៌ផង ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីផង ទើបកើតឡើង ព្រោះអញ្ញមញ្ញប្បច្ច័យ គឺ ខន្ធ ៣ អាស្រ័យវិបាកក្ខន្ធ ១ ផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ អាស្រ័យខន្ធ ២ ផង វត្ថុផង ។

(២០) វិបាកធម៌ អាស្រ័យវិបាកធម៌ ទើបកើតឡើង ព្រោះនិស្សយប្បច្ច័យ ។ សេចក្តីបំប្រួញ ។ ព្រោះឧបនិស្សយប្បច្ច័យ ព្រោះបុរេជាតប្បច្ច័យ ។

(២១) ធម៌មានវិបាកជាប្រក្រតី អាស្រ័យធម៌មានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះអាសេវនប្បច្ច័យ គឺ ខន្ធ ៣ អាស្រ័យខន្ធ ១ ដែលជាធម៌មានវិបាកជាប្រក្រតី ខន្ធ ២ អាស្រ័យខន្ធ ២ ។

(២២) ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះអាសេវនប្បច្ច័យ គឺ ខន្ធ ៣ អាស្រ័យខន្ធ ១ ដែលជាធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ខន្ធ ២ អាស្រ័យខន្ធ ២ ។

[២៣] វិបាកំ ធម្មំ បដិច្ច វិបាកោ ធម្មោ ឧប្បជ្ជតិ កម្មប្បច្ចយា ។ សង្ខិត្តំ ។ វិបាកប្បច្ចយា តីណិ ។

[២៤] នេវវិបាកនវិបាកធម្មធម្មំ បដិច្ច នេវវិបាកនវិបាកធម្មធម្មោ ឧប្បជ្ជតិ វិបាកប្បច្ចយា ឯកំ មហាភូតំ បដិច្ច តយោ មហាភូតា មហាភូតេ បដិច្ច ចិត្តសមុដ្ឋានំ រូបំ កដត្តារូបំ ឧបាទារូបំ ។ នេវវិបាកនវិបាកធម្មធម្មំ បដិច្ច វិបាកោ ធម្មោ ឧប្បជ្ជតិ វិបាកប្បច្ចយា បដិសន្ធិក្ខណេ វត្ថុំ បដិច្ច វិបាកា ខន្ធា ។ នេវវិបាកនវិបាកធម្មធម្មំ បដិច្ច វិបាកោ ច នេវវិបាកនវិបាកធម្មធម្មោ ច ធម្មា ឧប្បជ្ជន្តិ វិបាកប្បច្ចយា បដិសន្ធិក្ខណេ វត្ថុំ បដិច្ច វិបាកា ខន្ធា មហាភូតេ បដិច្ច កដត្តារូបំ ។

[២៥] វិបាកញ្ច នេវវិបាកនវិបាកធម្មធម្មញ្ច ធម្មំ បដិច្ច វិបាកោ ធម្មោ ឧប្បជ្ជតិ វិបាកប្បច្ចយា ។ បេ ។ នេវវិបាកនវិបាកធម្មធម្មោ ឧប្បជ្ជតិ វិបាកប្បច្ចយា ។ បេ ។ វិបាកោ ច នេវវិបាកនវិបាកធម្មធម្មោ ច ធម្មា ឧប្បជ្ជន្តិ វិបាកប្បច្ចយា ។

## វិបាកត្តិកៈ បដិច្ចវារៈ

[២៣] វិបាកធម៌ អាស្រ័យវិបាកធម៌ ទើបកើតឡើង ព្រោះកម្ម-បច្ច័យ ។ សេចក្ដីបំប្រួញ ។ ព្រោះវិបាកបច្ច័យ មានវារៈ ៣ ។

[២៤] ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះវិបាកបច្ច័យ គឺ មហាភូត ៣ អាស្រ័យមហាភូត ១ ចិត្តសមុដ្ឋានរូប កដត្តារូប ឧបាទារូប អាស្រ័យមហាភូតទាំងឡាយ ។ វិបាកធម៌ អាស្រ័យធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះវិបាកបច្ច័យ គឺ វិបាកក្ខន្ធទាំងឡាយ អាស្រ័យវត្ថុ ក្នុងខណៈនៃបដិសន្ធិ ។ វិបាកធម៌ក្តី ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីក្តី អាស្រ័យធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះវិបាកបច្ច័យ គឺ វិបាកក្ខន្ធទាំងឡាយ អាស្រ័យវត្ថុ ក្នុងខណៈនៃបដិសន្ធិ កដត្តារូប អាស្រ័យមហាភូតទាំង-ឡាយ ។

[២៥] វិបាកធម៌ អាស្រ័យវិបាកធម៌ផង ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីផង ទើបកើតឡើង ព្រោះវិបាកបច្ច័យ ។បេ។ ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះវិបាកបច្ច័យ ។បេ។ វិបាកធម៌ក្តី ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីក្តី ទើបកើតឡើង ព្រោះវិបាកបច្ច័យ ។

(២៦) វិបាកំ ធម្មំ បដិច្ច វិបាកោ ធម្មោ ឧប្បជ្ជតិ អាហារប្បច្ចយា ។ សង្ខិត្តំ ។ ឥន្ទ្រិយប្បច្ចយា ឈានប្បច្ចយា មគ្គប្បច្ចយា សម្បយុត្តប្បច្ចយា វិប្បយុត្តប្បច្ចយា អត្ថិប្បច្ចយា នត្ថិប្បច្ចយា វិគតប្បច្ចយា អវិគតប្បច្ចយា ។

(២៧) ហេតុយា តេរស អារម្មណេ បញ្ច អធិបតិយា នវ អនន្តរេ បញ្ច សមនន្តរេ បញ្ច សហជាតេ តេរស អញ្ញមញ្ញេ សត្ត និស្សយេ តេរស ឧបនិស្សយេ បញ្ច បុរេជាតេ តីណិ អាសេវនេ ទ្វេ កម្មេ តេរស វិបាកេ នវ អាហារេ តេរស ឥន្ទ្រិយេ តេរស ឈានេ តេរស មគ្គេ តេរស សម្បយុត្តេ បញ្ច វិប្បយុត្តេ តេរស អត្ថិយា តេរស នត្ថិយា បញ្ច វិគតេ បញ្ច អវិគតេ តេរស ។

(២៨) ហេតុប្បច្ចយា អារម្មណេ បញ្ច ។ បេ ។ អវិគតេ តេរស ។ យថា កុសលត្តិកស្ស គណនា ឯវំ គណេតព្វំ ។

(២៦) វិបាកធម៌ អាស្រ័យវិបាកធម៌ ទើបកើតឡើង ព្រោះអាហារប្បច្ច័យ ។ សេចក្តីបំប្រួញ ។ ព្រោះឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ នត្ថិប្បច្ច័យ វិគតប្បច្ច័យ និង អវិគតប្បច្ច័យ ។

(២៧) ក្នុងហេតុប្បច្ច័យ មានវារៈ ១៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៥ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៥ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៥ ក្នុងសហជាតប្បច្ច័យ មានវារៈ ១៣ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៧ ក្នុងនិស្សយប្បច្ច័យ មានវារៈ ១៣ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៥ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងអាសេវនប្បច្ច័យ មានវារៈ ២ ក្នុងកម្មប្បច្ច័យ មានវារៈ ១៣ ក្នុងវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងអាហារប្បច្ច័យ មានវារៈ ១៣ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ១៣ ក្នុងឈានប្បច្ច័យ មានវារៈ ១៣ ក្នុងមគ្គប្បច្ច័យ មានវារៈ ១៣ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ១៣ ក្នុងអត្ថិប្បច្ច័យ មានវារៈ ១៣ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៥ ក្នុងវិគតប្បច្ច័យ មានវារៈ ៥ ក្នុងអវិគតប្បច្ច័យ មានវារៈ ១៣ ។

(២៨) ក្នុងអារម្មណប្បច្ច័យ មានវារៈ ៥ ព្រោះហេតុប្បច្ច័យ ។ បេ ។ ក្នុងអវិគតប្បច្ច័យ មានវារៈ ១៣ ។ បណ្ឌិតគប្បីរាប់ ដូចជាការរាប់ នូវកុសលត្តិកៈដែរ ។

(២៩) អាសេវនប្បច្ចយា ហេតុយា ទ្វេ . . . អារម្មណេ ទ្វេ អធិបតិយា ទ្វេ អនន្តរេ ទ្វេ សមនន្តរេ ទ្វេ សហជាតេ ទ្វេ អញ្ញមញ្ញេ ទ្វេ និស្សយេ ទ្វេ ឧបនិស្សយេ ទ្វេ បុរេជាតេ ទ្វេ កម្មេ ទ្វេ អាហារេ ទ្វេ ឥន្ទ្រិយេ ទ្វេ ឈានេ ទ្វេ មគ្គេ ទ្វេ សម្បយុត្តេ ទ្វេ វិប្បយុត្តេ ទ្វេ អត្ថិយា ទ្វេ នត្ថិយា ទ្វេ វិគតេ ទ្វេ អវិគតេ ទ្វេ ។

(៣០) វិបាកប្បច្ចយា ហេតុយា នវ . . . អារម្មណេ តីណិ អធិបតិយា បញ្ច អនន្តរេ តីណិ សមនន្តរេ តីណិ សហជាតេ នវ អញ្ញមញ្ញេ ន និស្សយេ នវ ឧបនិស្សយេ តីណិ បុរេជាតេ ឯកំ កម្មេ នវ អាហារេ នវ ឥន្ទ្រិយេ នវ ឈានេ នវ

វិបាកត្តិក: បដិច្ចវារ:

[២៩] ក្នុងហេតុប្បច្ច័យ មានវារ: ២ ព្រោះអាសេវនប្បច្ច័យ . . . ក្នុងអារម្មណប្បច្ច័យ មានវារ: ២ ក្នុងអធិបតិប្បច្ច័យ មានវារ: ២ ក្នុងអនន្តរប្បច្ច័យ មានវារ: ២ ក្នុងសមនន្តរប្បច្ច័យ មានវារ: ២ ក្នុងសហជាតប្បច្ច័យ មានវារ: ២ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារ: ២ ក្នុងនិស្សយប្បច្ច័យ មានវារ: ២ ក្នុងឧបនិស្សយប្បច្ច័យ មានវារ: ២ ក្នុងបុរេជាតប្បច្ច័យ មានវារ: ២ ក្នុងកម្មប្បច្ច័យ មានវារ: ២ ក្នុងអាហារប្បច្ច័យ មានវារ: ២ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារ: ២ ក្នុងឈានប្បច្ច័យ មានវារ: ២ ក្នុងមគ្គប្បច្ច័យ មានវារ: ២ ក្នុងសម្បយុត្តប្បច្ច័យ មានវារ: ២ ក្នុងវិប្បយុត្តប្បច្ច័យ មានវារ: ២ ក្នុងអត្ថិប្បច្ច័យ មានវារ: ២ ក្នុងនត្ថិប្បច្ច័យ មានវារ: ២ ក្នុងវិគតប្បច្ច័យ មានវារ: ២ ក្នុងអវិគតប្បច្ច័យ មានវារ: ២ ។

[៣០] ក្នុងហេតុប្បច្ច័យ មានវារ: ៩ ព្រោះវិបាកប្បច្ច័យ . . . ក្នុងអារម្មណប្បច្ច័យ មានវារ: ៣ ក្នុងអធិបតិប្បច្ច័យ មានវារ: ៥ ក្នុងអនន្តរប្បច្ច័យ មានវារ: ៣ ក្នុងសមនន្តរប្បច្ច័យ មានវារ: ៣ ក្នុងសហជាតប្បច្ច័យ មានវារ: ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារ: ៦ ក្នុងនិស្សយប្បច្ច័យ មានវារ: ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារ: ៣ ក្នុងបុរេជាតប្បច្ច័យ មានវារ: ១ ក្នុងកម្មប្បច្ច័យ មានវារ: ៩ ក្នុងអាហារប្បច្ច័យ មានវារ: ៩ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារ: ៩ ក្នុងឈានប្បច្ច័យ មានវារ: ៩

មគ្គេ ទស សម្បយុត្តេ តីណិ វិប្បយុត្តេ ទស អត្ថិយា ទស នត្ថិយា តីណិ វិគតេ តីណិ អវិគតេ ទស ។

អនុលោមគណនា និដ្ឋិតា ។

(៣១) វិបាកំ ធម្មំ បដិច្ច វិបាកោ ធម្មោ ឧប្បជ្ជតិ នហេតុប្បច្ចយា អហេតុកំ វិបាកំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ទ្វេ ខន្ធេ បដិច្ច ទ្វេ ខន្ធា អហេតុកប្បដិសន្ធិក្ខណេ វិបាកំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា តយោ ខន្ធេ បដិច្ច ឯកោ ខន្ធោ ទ្វេ ខន្ធេ បដិច្ច ទ្វេ ខន្ធា ។ វិបាកំ ធម្មំ បដិច្ច នេវវិបាកនវិបាកធម្មធម្មោ ឧប្បជ្ជតិ នហេតុប្បច្ចយា អហេតុកវិបាកេ ខន្ធេ បដិច្ច ចិត្តសមុដ្ឋានំ រូបំ អហេតុកប្បដិសន្ធិក្ខណេ វិបាកេ ខន្ធេ បដិច្ច កដត្តារូបំ ។ វិបាកំ ធម្មំ បដិច្ច វិបាកោ ច នេវវិបាកនវិបាកធម្មធម្មោ ច ធម្មា ឧប្បជ្ជន្តិ នហេតុប្បច្ចយា អហេតុកំ វិបាកំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ចិត្តសមុដ្ឋានញ្ច រូបំ ទ្វេ ខន្ធេ បដិច្ច ទ្វេ ខន្ធា ចិត្តសមុដ្ឋានញ្ច រូបំ អហេតុកប្បដិសន្ធិក្ខណេ វិបាកំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា កដត្តា ច រូបំ ទ្វេ ខន្ធេ បដិច្ច ទ្វេ ខន្ធា កដត្តា ច រូបំ ។

ក្នុងមគ្គប្បច្ច័យ មានវារៈ ៩ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងវិគតប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

ចប់អនុលោមគណនា ។

[៣១] វិបាកធម៌ អាស្រ័យវិបាកធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺ ខន្ធ ៣ អាស្រ័យអហេតុកវិបាកក្ខន្ធ ១ ខន្ធ ២ អាស្រ័យខន្ធ ២ ខន្ធ ៣ អាស្រ័យវិបាកក្ខន្ធ ១ ក្នុងខណៈនៃអហេតុកបដិសន្ធិ ខន្ធ ១ អាស្រ័យខន្ធ ៣ ខន្ធ ២ អាស្រ័យខន្ធ ២ ។ ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យវិបាកធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺ ចិត្តសមុដ្ឋានរូប អាស្រ័យអហេតុកវិបាកក្ខន្ធទាំងឡាយ កដត្តារូប អាស្រ័យវិបាកក្ខន្ធទាំងឡាយ ក្នុងខណៈនៃអហេតុកបដិសន្ធិ ។ វិបាកធម៌ក្តី ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីក្តី អាស្រ័យវិបាកធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺ ខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យអហេតុកវិបាកក្ខន្ធ ១ ខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ២ ខន្ធ ៣ ក្តី កដត្តារូបក្តី អាស្រ័យវិបាកក្ខន្ធ ១ ក្នុងខណៈនៃអហេតុកបដិសន្ធិ ខន្ធ ២ ក្តី កដត្តារូបក្តី អាស្រ័យខន្ធ ២ ។

វិបាកត្តិកេ បដិច្ចវារោ

(៣២) វិបាកធម្មធម្មំ បដិច្ច វិបាកធម្មធម្មោ ឧប្បជ្ជតិ នហេតុប្បច្ចយា វិចិកិច្ឆាសហគតេ ឧទ្ធច្ចសហគតេ ខន្ធេ បដិច្ច វិចិកិច្ឆាសហគតោ ឧទ្ធច្ចសហគតោ មោហោ ។

(៣៣) នេវវិបាកនវិបាកធម្មធម្មំ បដិច្ច នេវវិបាកនវិបាកធម្មធម្មោ ឧប្បជ្ជតិ នហេតុប្បច្ចយា អហេតុកំ នេវវិបាកនវិបាកធម្មធម្មំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ចិត្តសមុដ្ឋានញ្ច រូបំ ទ្វេ ខន្ធេ បដិច្ច ទ្វេ ខន្ធា ចិត្តសមុដ្ឋានញ្ច រូបំ ឯកំ មហាភូតំ បដិច្ច តយោ មហាភូតា ទ្វេ មហាភូតេ បដិច្ច ទ្វេ មហាភូតា មហាភូតេ បដិច្ច ចិត្តសមុដ្ឋានំ រូបំ កដត្តារូបំ ឧបាទារូបំ ពាហិរំ . . . អាហារសមុដ្ឋានំ . . . ឧតុសមុដ្ឋានំ . . . អសញ្ញសត្តានំ ឯកំ មហាភូតំ បដិច្ច តយោ មហាភូតា មហាភូតេ បដិច្ច កដត្តារូបំ ឧបាទារូបំ ។ នេវវិបាកនវិបាកធម្មធម្មំ បដិច្ច វិបាកោ ធម្មោ ឧប្បជ្ជតិ នហេតុប្បច្ចយា អហេតុកបដិសន្ធិក្ខណេ វត្ថុំ បដិច្ច វិបាកា ខន្ធា ។ នេវវិបាកនវិបាកធម្មធម្មំ បដិច្ច វិបាកោ ច នេវវិបាកនវិបាកធម្មធម្មោ ច

(៣២) ធម៌មានវិបាកជាប្រក្រតី អាស្រ័យធម៌មានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺ មោហៈ ដែលច្រឡំដោយវិចិកិច្ឆា ច្រឡំដោយឧទ្ធច្ចៈ អាស្រ័យខន្ធទាំងឡាយ ដែលច្រឡំដោយវិចិកិច្ឆា ច្រឡំដោយឧទ្ធច្ចៈ ។

(៣៣) ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺ ខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យអហេតុកក្ខន្ធ ១ ដែលជាធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ២ មហាភូត ៣ អាស្រ័យមហាភូត ១ មហាភូត ២ អាស្រ័យមហាភូត ២ ចិត្តសមុដ្ឋានរូប កដត្តារូប ឧបាទារូប អាស្រ័យមហាភូតទាំងឡាយ ពាហិររូប... អាហារសមុដ្ឋានរូប...ឧតុសមុដ្ឋានរូប... មហាភូត ៣ អាស្រ័យមហាភូត ១ របស់ពួកអសញ្ញសត្វ កដត្តារូប ឧបាទារូប អាស្រ័យមហាភូតទាំងឡាយ ។ វិបាកធម៌ អាស្រ័យធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺ វិបាកក្ខន្ធទាំងឡាយ អាស្រ័យវត្ថុ ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ។ វិបាកធម៌ក្តី ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីក្តី អាស្រ័យធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី

ធម្មា ឧប្បជ្ជន្តិ នហេតុប្បច្ចយា អហេតុកប្បដិសន្ធិក្ខណេ វត្ថុំ បដិច្ច វិបាកា ខន្ធា មហាភូតេ បដិច្ច កដត្តារូបំ ។

(៣៨) វិបាកញ្ច នេវវិបាកនវិបាកធម្មធម្មញ្ច ធម្មំ បដិច្ច វិបាកោ ធម្មោ ឧប្បជ្ជតិ នហេតុប្បច្ចយា អហេតុកប្បដិសន្ធិក្ខណេ វិបាកំ ឯកំ ខន្ធញ្ច វត្ថុញ្ច បដិច្ច តយោ ខន្ធា ទ្វេ ខន្ធេ ច វត្ថុញ្ច បដិច្ច ទ្វេ ខន្ធា ។ វិបាកញ្ច នេវវិបាកនវិបាកធម្មធម្មញ្ច ធម្មំ បដិច្ច នេវវិបាកនវិបាកធម្មធម្មោ ឧប្បជ្ជតិ នហេតុប្បច្ចយា អហេតុកវិបាកេ ខន្ធេ ច មហាភូតេ ច បដិច្ច ចិត្តសមុដ្ឋានំ រូបំ អហេតុកប្បដិសន្ធិក្ខណេ វិបាកេ ខន្ធេ ច មហាភូតេ ច បដិច្ច កដត្តារូបំ ។ វិបាកញ្ច នេវវិបាកនវិបាកធម្មធម្មញ្ច ធម្មំ បដិច្ច វិបាកោ ច នេវវិបាកនវិបាកធម្មធម្មោ ច ធម្មា ឧប្បជ្ជន្តិ នហេតុប្បច្ចយា អហេតុកប្បដិសន្ធិក្ខណេ វិបាកំ ឯកំ ខន្ធញ្ច វត្ថុញ្ច បដិច្ច តយោ ខន្ធា ទ្វេ ខន្ធេ ច វត្ថុញ្ច បដិច្ច ទ្វេ ខន្ធា វិបាកេ ខន្ធេ ច មហាភូតេ ច បដិច្ច កដត្តារូបំ ។

ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺ វិបាកក្ខន្ធទាំងឡាយ អាស្រ័យវត្ថុ ក្នុងខណៈនៃអហេតុកប្បដិសន្ធិ កដត្តារូប អាស្រ័យមហាភូតទាំងឡាយ ។

(៣៨) វិបាកធម៌ អាស្រ័យវិបាកធម៌ផង ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺ ខន្ធ ៣ អាស្រ័យវិបាកក្ខន្ធ ១ ផង វត្ថុផង ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ខន្ធ ២ អាស្រ័យខន្ធ ២ ផង វត្ថុផង ។ ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យវិបាកធម៌ផង ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺ ចិត្តសមុដ្ឋានរូប អាស្រ័យអហេតុកវិបាកក្ខន្ធទាំងឡាយផង មហាភូតទាំងឡាយផង កដត្តារូប អាស្រ័យវិបាកក្ខន្ធទាំងឡាយផង មហាភូតទាំងឡាយផង ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ។ វិបាកធម៌ក្តី ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីក្តី អាស្រ័យវិបាកធម៌ផង ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺ ខន្ធ ៣ អាស្រ័យវិបាកក្ខន្ធ ១ ផង វត្ថុផង ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ខន្ធ ២ អាស្រ័យខន្ធ ២ ផង វត្ថុផង កដត្តារូប អាស្រ័យវិបាកក្ខន្ធទាំងឡាយផង មហាភូតទាំងឡាយផង ។

វិបាកត្តិកេ បដិច្ចវារោ

(៣៥) វិបាកំ ធម្មំ បដិច្ច នេវវិបាកនវិបាកធម្មធម្មោ ឧប្បជ្ជតិ នអារម្មណប្បច្ចយា វិបាកេ ខន្ធេ បដិច្ច ចិត្តសមុដ្ឋានំ រូបំ បដិសន្ធិក្ខណេ វិបាកេ ខន្ធេ បដិច្ច កដត្តារូបំ ។

(៣៦) វិបាកធម្មធម្មំ បដិច្ច នេវវិបាកនវិបាកធម្មធម្មោ ឧប្បជ្ជតិ នអារម្មណប្បច្ចយា វិបាកធម្មធម្មេ ខន្ធេ បដិច្ច ចិត្តសមុដ្ឋានំ រូបំ ។

(៣៧) នេវវិបាកនវិបាកធម្មធម្មំ បដិច្ច នេវវិបាកនវិបាកធម្មធម្មោ ឧប្បជ្ជតិ នអារម្មណប្បច្ចយា នេវវិបាកនវិបាកធម្មធម្មេ ខន្ធេ បដិច្ច ចិត្តសមុដ្ឋានំ រូបំ ឯកំ មហាភូតំ បដិច្ច តយោ មហាភូតា មហាភូតេ បដិច្ច ចិត្តសមុដ្ឋានំ រូបំ កដត្តារូបំ ឧបាទារូបំ ពាហិរំ . . . អាហារសមុដ្ឋានំ . . . ឧតុសមុដ្ឋានំ . . . អសញ្ញសត្តានំ ឯកំ មហាភូតំ បដិច្ច តយោ មហាភូតា មហាភូតេ បដិច្ច កដត្តារូបំ ឧបាទារូបំ ។

(៣៨) វិបាកញ្ច នេវវិបាកនវិបាកធម្មធម្មញ្ច ធម្មំ បដិច្ច នេវវិបាកនវិបាកធម្មធម្មោ ឧប្បជ្ជតិ

(៣៥) ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យវិបាកធម៌ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺ ចិត្តសមុដ្ឋានរូប អាស្រ័យវិបាកក្ខន្ធទាំងឡាយ កដត្តារូប អាស្រ័យវិបាកក្ខន្ធទាំងឡាយ ក្នុងខណៈនៃបដិសន្ធិ ។

(៣៦) ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យធម៌មានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺ ចិត្តសមុដ្ឋានរូប អាស្រ័យពួកខន្ធ ដែលជាធម៌មានវិបាកជាប្រក្រតី ។

(៣៧) ធម៌មិនមែនជាវិបាក មិនមែនមានវិបាក ជាប្រក្រតី អាស្រ័យធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺ ចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលជាធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី មហាភូត ៣ អាស្រ័យមហាភូត ១ ចិត្តសមុដ្ឋានរូប កដត្តារូប ឧបាទារូប អាស្រ័យមហាភូតទាំងឡាយ ពាហិររូប . . . អាហារសមុដ្ឋានរូប . . . ឧតុសមុដ្ឋានរូប . . . មហាភូត ៣ អាស្រ័យមហាភូត ១ របស់ពួកអសញ្ញសត្វ កដត្តារូប ឧបាទារូប អាស្រ័យមហាភូតទាំងឡាយ ។

(៣៨) ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យវិបាកធម៌ផង ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីផង ទើប

នអារម្មណប្បច្ចយា វិបាកេ ខន្ធេ ច មហាភូតេ ច បដិច្ច ចិត្តសមុដ្ឋានំ រូបំ បដិសន្ធិក្ខណេ វិបាកេ ខន្ធេ ច មហាភូតេ ច បដិច្ច កដត្តារូបំ ។

(៣៩) វិបាកធម្មធម្មញ្ច នេវវិបាកនវិបាកធម្មធម្មញ្ច ធម្មំ បដិច្ច នេវវិបាកនវិបាកធម្មធម្មោ ឧប្បជ្ជតិ នអារម្មណប្បច្ចយា វិបាកធម្មធម្មេ ខន្ធេ ច មហាភូតេ ច បដិច្ច ចិត្តសមុដ្ឋានំ រូបំ ។

(៤០) វិបាកំ ធម្មំ បដិច្ច វិបាកោ ធម្មោ ឧប្បជ្ជតិ នអធិបតិប្បច្ចយា ។ យថា អនុលោមំ សហជាតសទិសំ សង្ខិត្តំ ។

(៤១) វិបាកំ ធម្មំ បដិច្ច នេវវិបាកនវិបាកធម្មធម្មោ ឧប្បជ្ជតិ នអនន្តរប្បច្ចយា . . . នសមនន្តរប្បច្ចយា នអញ្ញមញ្ញប្បច្ចយា មហាភូតេ បដិច្ច ចិត្តសមុដ្ឋានំ រូបំ កដត្តារូបំ ឧបាទារូបំ ពាហិរំ . . . អាហារសមុដ្ឋានំ . . . ឧតុសមុដ្ឋានំ . . . អសញ្ញសត្តានំ មហាភូតេ បដិច្ច កដត្តារូបំ ឧបាទារូបំ ឥទំ នានត្តំ នអញ្ញមញ្ញប្បច្ចយា នឧបនិស្សយប្បច្ចយា ។

កើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺ ចិត្តសមុដ្ឋានរូប អាស្រ័យវិបាកក្ខន្ធទាំងឡាយផង មហាភូតទាំងឡាយផង កដត្តារូប អាស្រ័យវិបាកក្ខន្ធទាំងឡាយផង មហាភូតទាំងឡាយផង ក្នុងខណៈនៃបដិសន្ធិ ។

(៣៩) ធម៌មិនមែនជាវិបាក មិនមែនមានវិបាក ជាប្រក្រតី អាស្រ័យធម៌មានវិបាកជាប្រក្រតីផង ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីផង ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺ ចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលជាធម៌ មានវិបាកជាប្រក្រតីផង មហាភូតទាំងឡាយផង ។

(៤០) វិបាកធម៌ អាស្រ័យវិបាកធម៌ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ ។ អនុលោម ប្រហែលគ្នានឹងសហជាតប្បច្ច័យ តាមដែលលោកបំប្រួញហើយ ។

(៤១) ធម៌មិនមែនជាវិបាក មិនមែនមានវិបាក ជាប្រក្រតី អាស្រ័យវិបាកធម៌ ទើបកើតឡើង ព្រោះនអនន្តរប្បច្ច័យ . . . ព្រោះនសមនន្តរប្បច្ច័យ ព្រោះនអញ្ញមញ្ញប្បច្ច័យ គឺ ចិត្តសមុដ្ឋានរូប កដត្តារូប ឧបាទារូប អាស្រ័យមហាភូតទាំងឡាយ ពាហិររូប . . . អាហារសមុដ្ឋានរូប . . . ឧតុសមុដ្ឋានរូប . . . កដត្តារូប ឧបាទារូប អាស្រ័យមហាភូតទាំងឡាយ របស់ពួកអសញ្ញសត្វ សេចក្តីផ្សេង ៗ គ្មាននេះ ព្រោះនអញ្ញមញ្ញប្បច្ច័យ ព្រោះនឧបនិស្សយប្បច្ច័យ ។

## វិបាកត្តិកេ បដិច្ចវារោ

(៤២) វិបាកំ ធម្មំ បដិច្ច វិបាកោ ធម្មោ ឧប្បជ្ជតិ ហេតុបច្ចយា អារុប្បេ វិបាកំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ទ្វេ ខន្ធេ បដិច្ច ទ្វេ ខន្ធា បដិសន្ធិក្ខណេ វិបាកំ ឯកំ ខន្ធំ ។ សង្ខិត្តំ ។ វិបាកំ ធម្មំ បដិច្ច នេវវិបាកនវិបាកធម្មធម្មោ ឧប្បជ្ជតិ ហេតុបច្ចយា វិបាកេ ខន្ធេ បដិច្ច ចិត្ត-សមុដ្ឋានំ រូបំ បដិសន្ធិក្ខណេ ។ សង្ខិត្តំ ។ វិបាកំ ធម្មំ បដិច្ច វិបាកោ ច នេវវិបាកនវិបាកធម្មធម្មោ ច ធម្មា ឧប្បជ្ជន្តិ ហេតុបច្ចយា បដិសន្ធិក្ខណេ វិបាកំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា កដត្តា ច រូបំ ទ្វេ ខន្ធេ បដិច្ច ទ្វេ ខន្ធា កដត្តា ច រូបំ ។

(៤៣) វិបាកធម្មធម្មំ បដិច្ច វិបាកធម្មធម្មោ ឧប្បជ្ជតិ ហេតុបច្ចយា អារុប្បេ វិបាកធម្មធម្មំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ទ្វេ ខន្ធេ បដិច្ច ទ្វេ ខន្ធា ។ វិបាកធម្មធម្មំ បដិច្ច នេវវិបាកនវិ-បាកធម្មធម្មោ ឧប្បជ្ជតិ ហេតុបច្ចយា វិបាក-ធម្មធម្មេ ខន្ធេ បដិច្ច ចិត្តសមុដ្ឋានំ រូបំ ។

វិបាកត្តិកៈ បដិច្ចវារៈ

(៤២) វិបាកធម៌ អាស្រ័យវិបាកធម៌ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺ ខន្ធ ៣ អាស្រ័យវិបាកខន្ធ ១ ក្នុងអរូបភព ខន្ធ ២ អាស្រ័យខន្ធ ២ (ខន្ធទាំងឡាយ) អាស្រ័យវិបាកខន្ធ ១ ក្នុងខណៈនៃបដិសន្ធិ ។ សេចក្តីបំប្រួញ ។ ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យវិបាកធម៌ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺ ចិត្តសមុដ្ឋានរូប អាស្រ័យវិបាកខន្ធទាំងឡាយ ក្នុងខណៈនៃបដិសន្ធិ ។ សេចក្តីបំប្រួញ ។ វិបាកធម៌ក្តី ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីក្តី អាស្រ័យវិបាកធម៌ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺ ខន្ធ ៣ ក្តី កដត្តារូបក្តី អាស្រ័យវិបាកខន្ធ ១ ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ ក្តី កដត្តារូបក្តី អាស្រ័យខន្ធ ២ ។

(៤៣) ធម៌មានវិបាកជាប្រក្រតី អាស្រ័យធម៌មានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺ ខន្ធ ៣ អាស្រ័យខន្ធ ១ ដែលជាធម៌មានវិបាកជាប្រក្រតី ក្នុងអរូបភព ខន្ធ ២ អាស្រ័យខន្ធ ២ ។ ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យធម៌មានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺ ចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលជាធម៌មានវិបាកជាប្រក្រតី ។

(៦៦) នេវវិបាកនវិបាកធម្មធម្មំ បដិច្ច នេវវិបាកនវិបាកធម្មធម្មោ ឧប្បជ្ជតិ នបុរេជាតប្បច្ចយា អារុប្បេ នេវវិបាកនវិបាកធម្មធម្មំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ទ្វេ ខន្ធេ បដិច្ច ទ្វេ ខន្ធា នេវវិបាកនវិបាកធម្មធម្មេ ខន្ធេ បដិច្ច ចិត្តសមុដ្ឋានំ រូបំ ឯកំ មហាភូតំ បដិច្ច តយោ មហាភូតា ពាហិរំ ... អាហារសមុដ្ឋានំ ... ឧតុសមុដ្ឋានំ ... អសញ្ញសត្តានំ ឯកំ មហាភូតំ បដិច្ច ។ នេវវិបាកនវិបាកធម្មធម្មំ បដិច្ច វិបាកោ ធម្មោ ឧប្បជ្ជតិ នបុរេជាតប្បច្ចយា បដិសន្ធិក្ខណេ វត្ថុំ បដិច្ច វិបាកា ខន្ធា ។ នេវវិបាកនវិបាកធម្មធម្មំ បដិច្ច វិបាកោ ច នេវវិបាកនវិបាកធម្មធម្មោ ច ធម្មា ឧប្បជ្ជន្តិ នបុរេជាតប្បច្ចយា បដិសន្ធិក្ខណេ វត្ថុំ បដិច្ច វិបាកា ខន្ធា មហាភូតេ បដិច្ច កដត្តារូបំ ។

(៦៧) វិបាកញ្ច នេវវិបាកនវិបាកធម្មធម្មញ្ច ធម្មំ បដិច្ច វិបាកោ ធម្មោ ឧប្បជ្ជតិ នបុរេជាតប្បច្ចយា

[ ៤៤ ] ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺ ខន្ធ ៣ អាស្រ័យខន្ធ ១ ដែលជាធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ក្នុងអរូបភព ខន្ធ ២ អាស្រ័យខន្ធ ២ ចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលជាធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី មហាភូត ៣ អាស្រ័យមហាភូត ១ ពាហិររូប . . . អាហារសមុដ្ឋានរូប . . . ឧតុសមុដ្ឋានរូប . . . (មហាភូត ៣) អាស្រ័យមហាភូត ១ របស់ពួកអសញ្ញសត្វ ។ វិបាកធម៌ អាស្រ័យធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺ វិបាកក្ខន្ធទាំងឡាយ អាស្រ័យវត្ថុ ក្នុងខណៈនៃបដិសន្ធិ ។ វិបាកធម៌ក្តី ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីក្តី អាស្រ័យធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺវិបាកក្ខន្ធទាំងឡាយ អាស្រ័យវត្ថុ ក្នុងខណៈនៃបដិសន្ធិ កដត្តារូប អាស្រ័យមហាភូតទាំងឡាយ ។

[ ៤៥ ] វិបាកធម៌ អាស្រ័យវិបាកធម៌ផង ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីផង ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ

បដិសន្ធិក្ខណេ វិបាកំ ឯកំ ខន្ធញ្ច វត្ថុញ្ច បដិច្ច តយោ ខន្ធា ទ្វេ ខន្ធេ ច វត្ថុញ្ច បដិច្ច ទ្វេ ខន្ធា ។ វិបាកញ្ច នេវវិបាកនវិបាកធម្មធម្មញ្ច ធម្មំ បដិច្ច នេវវិបាកនវិបាកធម្មធម្មោ ឧប្បជ្ជតិ នបុរេ-ជាតប្បច្ចយា វិបាកេ ខន្ធេ ច មហាភូតេ ច បដិច្ច ចិត្តសមុដ្ឋានំ រូបំ បដិសន្ធិក្ខណេ វិបាកេ ខន្ធេ ច មហាភូតេ ច បដិច្ច កដត្តារូបំ ។ វិបាកញ្ច នេវវិបាកនវិបាកធម្មធម្មញ្ច ធម្មំ បដិច្ច វិបាកោ ច នេវវិបាកនវិបាកធម្មធម្មោ ច ធម្មា ឧប្បជ្ជន្តិ នបុរេ-ជាតប្បច្ចយា បដិសន្ធិក្ខណេ វិបាកំ ឯកំ ខន្ធញ្ច វត្ថុញ្ច បដិច្ច តយោ ខន្ធា ទ្វេ ខន្ធេ ច វត្ថុញ្ច បដិច្ច ទ្វេ ខន្ធា វិបាកេ ខន្ធេ ច មហាភូតេ ច បដិច្ច កដត្តារូបំ ។

(៤២) វិបាកធម្មធម្មញ្ច នេវវិបាកនវិបាកធម្ម-ធម្មញ្ច ធម្មំ បដិច្ច នេវវិបាកនវិបាកធម្មធម្មោ ឧប្ប-ជ្ជតិ នបុរេជាតប្បច្ចយា វិបាកធម្មធម្មេ ខន្ធេ ច មហាភូតេ ច បដិច្ច ចិត្តសមុដ្ឋានំ រូបំ ។ វិបាកំ ធម្មំ បដិច្ច វិបាកោ ធម្មោ ឧប្បជ្ជតិ នបច្ឆាជាតប្ប-ច្ចយា ។ សង្ខិត្តំ ។ . . . នអាសេវនប្បច្ចយា ។

គឺ ខន្ធ ៣ អាស្រ័យវិបាកក្ខន្ធ ១ ផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ អាស្រ័យខន្ធ ២ ផង វត្ថុផង ។ ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យវិបាកធម៌ផង ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីផង ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺ ចិត្តសមុដ្ឋានរូប អាស្រ័យវិបាកក្ខន្ធទាំងឡាយផង មហាភូតទាំងឡាយផង កដត្តារូប អាស្រ័យវិបាកក្ខន្ធទាំងឡាយផង មហាភូតទាំងឡាយផង ក្នុងខណៈនៃបដិសន្ធិ ។ វិបាកធម៌ក្តី ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីក្តី អាស្រ័យវិបាកធម៌ផង ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីផង ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺ ខន្ធ ៣ អាស្រ័យវិបាកក្ខន្ធ ១ ផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ អាស្រ័យខន្ធ ២ ផង វត្ថុផង កដត្តារូប អាស្រ័យវិបាកក្ខន្ធទាំងឡាយផង មហាភូតទាំងឡាយផង ។

[ ៤៦ ] ធម៌មិនមែនជាវិបាក មិនមែនមានវិបាក ជាប្រក្រតី អាស្រ័យធម៌មានវិបាកជាប្រក្រតីផង ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីផង ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺ ចិត្ត-សមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលជាធម៌មានវិបាកជាប្រក្រតីផង មហាភូតទាំងឡាយផង ។ វិបាកធម៌ អាស្រ័យវិបាកធម៌ ទើបកើតឡើង ព្រោះនបច្ឆាជាតប្បច្ច័យ ។ សេចក្តីបំប្រួញ ។ ព្រោះនអាសេវនប្បច្ច័យ ។

វិបាកធម្មធម្មំ បដិច្ច វិបាកធម្មធម្មោ ឧប្បជ្ជតិ នកម្មប្បច្ចយា វិបាកធម្មធម្មេ ខន្ធេ បដិច្ច វិបាក-ធម្មធម្មា ចេតនា ។

(៤៧) នេវវិបាកនវិបាកធម្មធម្មំ បដិច្ច នេវវិ-បាកនវិបាកធម្មធម្មោ ឧប្បជ្ជតិ នកម្មប្បច្ចយា នេវ-វិបាកនវិបាកធម្មធម្មេ ខន្ធេ បដិច្ច នេវវិបាកនវិបាក-ធម្មធម្មា ចេតនា ពាហិរំ . . . អាហារសមុដ្ឋានំ . . . ឧតុសមុដ្ឋានំ ឯកំ មហាភូតំ បដិច្ច តយោ មហាភូតា មហាភូតេ បដិច្ច ឧបាទារូបំ ។

(៤៨) វិបាកធម្មធម្មំ បដិច្ច វិបាកធម្មធម្មោ ឧប្បជ្ជតិ នវិបាកប្បច្ចយា វិបាកធម្មធម្មំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ទ្វេ ខន្ធេ បដិច្ច ទ្វេ ខន្ធា ។ វិបាកធម្មធម្មំ បដិច្ច នេវវិបាកនវិបាកធម្មធម្មោ ឧប្បជ្ជតិ នវិបាកប្បច្ចយា វិបាកធម្មធម្មេ ខន្ធេ បដិច្ច ចិត្តសមុដ្ឋានំ រូបំ ។ វិបាកធម្មធម្មំ បដិច្ច វិបាកធម្ម-ធម្មោ ច នេវវិបាកនវិបាកធម្មធម្មោ ច ធម្មា ឧប្បជ្ជន្តិ នវិបាកប្បច្ចយា វិបាកធម្មធម្មំ ឯកំ ខន្ធំ បដិច្ច តយោ

ធម៌មានវិបាកជាប្រក្រតី អាស្រ័យធម៌មានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះនកម្មប្បច្ច័យ គឺ ចេតនា ជាធម៌មានវិបាកជាប្រក្រតី អាស្រ័យខន្ធទាំងឡាយ ដែលជាធម៌មានវិបាកជាប្រក្រតី ។

(៤៧) ធម៌មិនមែនជាវិបាក មិនមែនមានវិបាក ជាប្រក្រតី អាស្រ័យធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះនកម្មប្បច្ច័យ គឺ ចេតនា ជាធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យខន្ធទាំងឡាយ ដែលជាធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ពាហិររូប . . . អាហារសមុដ្ឋានរូប . . . ឧតុសមុដ្ឋានរូប . . . មហាភូត ៣ អាស្រ័យមហាភូត ១ ឧបាទារូប អាស្រ័យមហាភូតទាំងឡាយ ។

(៤៨) ធម៌មានវិបាកជាប្រក្រតី អាស្រ័យធម៌មានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះនវិបាកប្បច្ច័យ គឺ ខន្ធ ៣ អាស្រ័យខន្ធ ១ ដែលជាធម៌មានវិបាកជាប្រក្រតី ខន្ធ ២ អាស្រ័យខន្ធ ២ ។ ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យធម៌មិនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះនវិបាកប្បច្ច័យ គឺ ចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលជាធម៌មានវិបាកជាប្រក្រតី ។ ធម៌មានវិបាកជាប្រក្រតីក្តី ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីក្តី អាស្រយធម៌មានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះនវិបាកប្បច្ច័យ គឺ ខន្ធ ៣ ក្តី

ខន្ធា ចិត្តសមុដ្ឋានញ្ច រូបំ ទ្វេ ខន្ធេ បដិច្ច ទ្វេ ខន្ធា ចិត្តសមុដ្ឋានញ្ច រូបំ ។

(៤៩) នេវវិបាកនវិបាកធម្មធម្មំ បដិច្ច នេវវិបាកនវិបាកធម្មធម្មោ ឧប្បជ្ជតិ នវិបាកប្បច្ចយា នេវវិបាកនវិបាកធម្មធម្មំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ចិត្តសមុដ្ឋានញ្ច រូបំ ទ្វេ ខន្ធេ បដិច្ច ទ្វេ ខន្ធា ចិត្តសមុដ្ឋានញ្ច រូបំ ឯកំ មហាភូតំ បដិច្ច តយោ មហាភូតា មហាភូតេ បដិច្ច ចិត្តសមុដ្ឋានំ រូបំ ឧបាទារូបំ ពាហិរំ . . . អាហារសមុដ្ឋានំ . . . ឧតុសមុដ្ឋានំ . . . អសញ្ញសត្តានំ ឯកំ មហាភូតំ បដិច្ច តយោ មហាភូតា មហាភូតេ បដិច្ច កដត្តារូបំ ឧបាទារូបំ ។

(៥០) វិបាកធម្មធម្មញ្ច នេវវិបាកនវិបាកធម្មធម្មញ្ច ធម្មំ បដិច្ច នេវវិបាកនវិបាកធម្មធម្មោ ឧប្បជ្ជតិ នវិបាកប្បច្ចយា វិបាកធម្មធម្មេ ខន្ធេ ច មហាភូតេ ច បដិច្ច ចិត្តសមុដ្ឋានំ រូបំ ។

(៥១) នេវវិបាកនវិបាកធម្មធម្មំ បដិច្ច នេវវិបាកនវិបាកធម្មធម្មោ ឧប្បជ្ជតិ នអាហារប្បច្ចយា ពាហិរំ . . . អាហារសមុដ្ឋានំ . . . ឧតុសមុដ្ឋានំ . . .

សមុដ្ឋានរូបក្តី អាស្រ័យខន្ធ ១ ដែលជាធម៌មានវិបាកជាប្រក្រតី ខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ២ ។

[៤៩] ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យធម៌មិនមែនជាវិបាក មិនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះនវិបាកប្បច្ច័យ គឺ ខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ១ ដែលជាធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ២ មហាភូត ៣ អាស្រ័យមហាភូត ១ ចិត្តសមុដ្ឋានរូប ឧបាទារូប អាស្រ័យមហាភូតទាំងឡាយ ពាហិររូប . . . អាហារសមុដ្ឋានរូប . . . ឧតុសមុដ្ឋានរូប . . . មហាភូត ៣ អាស្រ័យមហាភូត ១ របស់ពួកអសញ្ញសត្វ កដត្តារូប ឧបាទារូប អាស្រ័យមហាភូតទាំងឡាយ ។

[៥០] ធម៌មិនមែនជាវិបាក មិនមែនមានជាប្រក្រតី អាស្រ័យធម៌មានវិបាកជាប្រក្រតីផង ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីផង ទើបកើតឡើង ព្រោះនវិបាកប្បច្ច័យ គឺ ចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលជាធម៌មានវិបាកជាប្រក្រតីផង មហាភូតទាំងឡាយផង ។

[៥១] ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះន-អាហារប្បច្ច័យ គឺ ពាហិររូប ... អាហារសមុដ្ឋានរូប ... ឧតុសមុដ្ឋានរូប ...

អសញ្ញសត្តានំ ឯកំ មហាភូតំ បដិច្ច តយោ មហាភូតា មហាភូតេ បដិច្ច កដត្តារូបំ ឧបាទារូបំ ។

(៤២) នេវវិបាកនវិបាកធម្មធម្មំ បដិច្ច នេវវិបាកនវិបាកធម្មោ ឧប្បជ្ជតិ នឥន្ទ្រិយប្បច្ចយា ពាហិរំ . . . អាហារសមុដ្ឋានំ . . . ឧតុសមុដ្ឋានំ . . . ឯកំ មហាភូតំ បដិច្ច តយោ មហាភូតា អសញ្ញសត្តានំ មហាភូតេ បដិច្ច រូបជីវិតិន្ទ្រិយំ ។

(៤៣) វិបាកំ ធម្មំ បដិច្ច វិបាកោ ធម្មោ ឧប្បជ្ជតិ នឈានប្បច្ចយា បញ្ចវិញ្ញាណសហគតំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ទ្វេ ខន្ធេ បដិច្ច ទ្វេ ខន្ធា ។

(៤៤) នេវវិបាកនវិបាកធម្មធម្មំ បដិច្ច នេវវិបាកនវិបាកធម្មោ ឧប្បជ្ជតិ នឈានប្បច្ចយា ពាហិរំ . . . អាហារសមុដ្ឋានំ . . . ឧតុសមុដ្ឋានំ អសញ្ញសត្តានំ ឯកំ មហាភូតំ បដិច្ច ។ បេ ។

(៤៥) វិបាកំ ធម្មំ បដិច្ច វិបាកោ ធម្មោ ឧប្បជ្ជតិ នមគ្គប្បច្ចយា អហេតុកំ វិបាកំ ឯកំ ខន្ធំ បដិច្ច តីណិ ។

(៤៦) នេវវិបាកនវិបាកធម្មធម្មំ បដិច្ច នេវវិបាកនវិបាកធម្មោ ឧប្បជ្ជតិ នមគ្គប្បច្ចយា អហេតុកំ

មហាភូត ៣ អាស្រ័យមហាភូត ១ របស់ពួកអសញ្ញសត្វ កដត្តារូប ឧបាទារូប អាស្រ័យមហាភូតទាំងឡាយ ។

(៥២) ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះនត្ថិន្ទ្រិយប្បច្ច័យ គឺ ពាហិររូប . . . អាហារសមុដ្ឋានរូប . . . ឧតុ-សមុដ្ឋានរូប . . . មហាភូត ៣ អាស្រ័យមហាភូត ១ រូបជីវិតិន្ទ្រិយ អាស្រ័យមហាភូតទាំងឡាយ របស់ពួកអសញ្ញសត្វ ។

(៥៣) វិបាកធម៌ អាស្រ័យវិបាកធម៌ ទើបកើតឡើង ព្រោះនឈានប្បច្ច័យ គឺ ខន្ធ ៣ អាស្រ័យខន្ធ ១ ដែលប្រកបដោយបញ្ចវិញ្ញាណ ខន្ធ ២ អាស្រ័យខន្ធ ២ ។

(៥៤) ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះនឈានប្បច្ច័យ គឺ ពាហិររូប . . . អាហារសមុដ្ឋានរូប . . . ឧតុសមុដ្ឋាន-រូប . . . មហាភូត ៣ អាស្រ័យមហាភូត ១ របស់ពួកអសញ្ញសត្វ ។ បេ ។

(៥៥) វិបាកធម៌ អាស្រ័យវិបាកធម៌ ទើបកើតឡើង ព្រោះនមគ្គប្បច្ច័យ គឺ ខន្ធ ៣ អាស្រ័យអហេតុកវិបាកក្ខន្ធ ១ ។

(៥៦) ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះនមគ្គប្បច្ច័យ គឺ ខន្ធ ៣ អាស្រ័យខន្ធ ១ ដែលជាអហេតុកៈ

នេវវិបាកនវិបាកធម្មធម្មំ ឯកំ ខន្ធំ បដិច្ច តីណិ ។

(៥៧) វិបាកញ្ច នេវវិបាកនវិបាកធម្មធម្មញ្ច ធម្មំ បដិច្ច វិបាកោ ធម្មោ ឧប្បជ្ជតិ នមគ្គប្បច្ចយា អហេតុកប្បដិសន្ធិក្ខណេ វិបាកំ ឯកំ ខន្ធញ្ច វត្ថុញ្ច បដិច្ច តីណិ ។

(៥៨) វិបាកំ ធម្មំ បដិច្ច នេវវិបាកនវិបាក-ធម្មធម្មោ ឧប្បជ្ជតិ នសម្បយុត្តប្បច្ចយា ទ្វេ ។ វិបាកធម្មធម្មំ បដិច្ច នេវវិបាកនវិបាកធម្មធម្មោ ឧប្បជ្ជតិ នសម្បយុត្តប្បច្ចយា ទ្វេ ។ នេវវិបាកន-វិបាកធម្មធម្មំ បដិច្ច ឯកំ ។

(៥៩) វិបាកំ ធម្មំ បដិច្ច វិបាកោ ធម្មោ ឧប្បជ្ជតិ នវិប្បយុត្តប្បច្ចយា អារុប្បេ វិបាកំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ទ្វេ ខន្ធេ បដិច្ច តយោ ខន្ធា ទ្វេ ខន្ធេ បដិច្ច ទ្វេ ខន្ធា ។

(៦០) វិបាកធម្មធម្មំ បដិច្ច វិបាកធម្មធម្មោ ឧប្បជ្ជតិ នវិប្បយុត្តប្បច្ចយា អារុប្បេ វិបាកធម្មធម្មំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ទ្វេ ខន្ធេ បដិច្ច ទ្វេ ខន្ធា ។

ជាធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ។

(៥៧) វិបាកធម៌ អាស្រ័យវិបាកធម៌ផង ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតីផង ទើបកើតឡើង ព្រោះនមគ្គប្បច្ច័យ គឺ ខន្ធ ៣ អាស្រ័យវិបាកក្ខន្ធ ១ ផង វត្ថុផង ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ។

(៥៨) ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាក្រប្រតី អាស្រ័យវិបាកធម៌ ទើបកើតឡើង ព្រោះនសម្បយុត្តប្បច្ច័យ គឺ ខន្ធ ២ ។ ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី អាស្រ័យធម៌មានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះនសម្បយុត្តប្បច្ច័យ គឺ ខន្ធ ២ ។ ខន្ធ ១ អាស្រ័យធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ។

(៥៩) វិបាកធម៌ អាស្រ័យវិបាកធម៌ ទើបកើតឡើង ព្រោះនវិប្បយុត្តប្បច្ច័យ គឺ ខន្ធ ៣ អាស្រ័យវិបាកក្ខន្ធ ១ ក្នុងអរូបភព ខន្ធ ៣ អាស្រ័យខន្ធ ២ ខន្ធ ២ អាស្រ័យខន្ធ ២ ។

